ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២ សជណ.កបច

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ
# អនុសញ្ញាមីណាម៉ាតាស្តីពីបារត

អនុសញ្ញាមីណាម៉ាតាស្តីពីបារត ត្រូវបានអនុម័តនិងដាក់ឱ្យចុះហត្ថលេខានាថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ នៅទីក្រុងគូម៉ាម៉ូតូនៃប្រទេសជប៉ុន ហើយបានចូលជាធរមាននៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧។ បច្ចុប្បន្ន ប្រទេសចំនួន១២៨បានចុះហត្ថលេខាលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត ដែលក្នុងចំណោមប្រទេសហត្ថលេខីទាំងអស់មានប្រទេសចំនួន១១៦បានផ្តល់សច្ចាប័នលើអនុសញ្ញានេះរួចហើយ។ ព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញាមីណាម៉ាតា នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ក្នុងសន្និសីទពេញអង្គដែលបានរៀបចំឡើងនៅទីក្រុងគូម៉ាម៉ូតូនៃប្រទេសជប៉ុន។

អនុសញ្ញាមីណាម៉ាតាមានគោលបំណងដើម្បីការពារសុខភាពមនុស្ស និងគាំពារបរិស្ថានពីការបញ្ចេញនិងការសាយភាយបារតនិងសមាសធាតុបារត ដែលបង្កឡើងដោយសកម្មភាពមនុស្ស។ តាមការសិក្សារបស់កម្មវិធីបរិស្ថានសហប្រជាជាតិបានរកឃើញថា បរិមាណបារតពី ៥ ៥០០តោន ទៅ ៨ ៩០០តោន ត្រូវបានបញ្ចេញនិងសាយភាយចូលទៅក្នុងបរិស្ថានជារៀងរាល់ឆ្នាំ ដែលក្នុងនោះ ៩០% បង្កឡើងពីសកម្មភាពមនុស្ស។ បារតត្រូវបានចាត់ទុកជាសារធាតុគីមីគ្រោះថ្នាក់ដែលមានកម្រិតពុលខ្ពស់ មិនងាយបំបែកធាតុ និងផ្លាស់ទីបានចម្ងាយឆ្ងាយ ហើយអាចបង្កហានិភ័យខ្ពស់ដល់សុខភាពមនុស្ស រួមមានការបង្កផលប៉ះពាល់លើប្រព័ន្ធប្រសាទនិងប្រព័ន្ធភាពស៊ាំ និងការរីកលូតលាស់របស់ទារកក្នុងផ្ទៃ ព្រមទាំងបង្កឱ្យមានជំងឺមហារីកនិងជំងឺរ៉ាំរ៉ៃផ្សេងទៀត។

អនុសញ្ញាមីណាម៉ាតាបានដាក់ចេញវិធានការចាំបាច់សម្រាប់ប្រទេស ដែលជាភាគីក្នុងការកាត់បន្ថយ និងទប់ស្កាត់ការបញ្ចេញ និងការសាយភាយបារត និងសមាសធាតុបារតទៅក្នុងបរិស្ថាន តាមរយៈការកម្រិតនិងការហាមឃាត់លើការផ្គត់ផ្គង់ ការប្រើប្រាស់ ការធ្វើពាណិជ្ជកម្ម ការនាំចូលនិងការនាំចេញ និងការគ្រប់គ្រងសំណល់មានផ្ទុកបារត។ ជាមួយគ្នានេះដែរ ប្រទេសចូលជាភាគីនៃអនុសញ្ញានេះនឹងទទួលបានជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុពីប្រទេសអភិវឌ្ឍនិងអង្គការអន្តរជាតិពាក់ព័ន្ធសម្រាប់ការអនុវត្តវិធានចាំបាច់ដែលបញ្ញត្តិនៅក្នុងអនុសញ្ញាមីណាម៉ាតាស្តីពីបារត។

អនុសញ្ញាមីណាម៉ាតាស្តីពីបារត មានចំនួន៣៥មាត្រា ដែលមានខ្លឹមសារសង្ខេបសំខាន់ៗ ដូចតទៅៈ មាត្រា១-កម្មវត្ថុ, មាត្រា២-និយមន័យ, មាត្រា៣-ប្រភពផ្គត់ផ្គង់និងការធ្វើពាណិជ្ជកម្មបារត, មាត្រា៤-ផលិតផលមានបន្ថែមបារត, មាត្រា៥-ប្រព័ន្ធផលិតកម្មដែលប្រើបារតឬសមាសធាតុបារត, មាត្រា៦-ការផ្តល់ការលើកលែងដល់ភាគីស្នើសុំ, មាត្រា៧-អាជីវកម្មរ៉ែមាសខ្នាតតូច, មាត្រា៨-ការបញ្ចេញ, មាត្រា៩-ការសាយភាយ, មាត្រា១០-ការស្តុកទុកបណ្តោះអាសន្នបារតនិងសំណល់បារតផ្សេងទៀតប្រកបដោយសុវត្ថិភាពបរិស្ថាន, មាត្រា១១-សំណល់បារត, មាត្រា១២-ទីតាំងដែលទទួលរងការបំពុល, មាត្រា១៣-ធនធាននិងយន្តការហិរញ្ញវត្ថុ, មាត្រា១៤-ការកសាងសមត្ថភាព ការផ្តល់ជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យា, មាត្រា១៥-គណៈកម្មាធិការប្រតិបត្តិនិងត្រួតពិនិត្យ, មាត្រា១៦-ផ្នែកសុខភាព, មាត្រា១៧-ការផ្លាស់ប្តូរព័ត៌មាន, មាត្រា១៨-ព័ត៌មានសាធារណៈ ចំណេះដឹង និងការអប់រំ, មាត្រា១៩-ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងការអង្កេតតាមដាន, មាត្រា២០-ផែនការអនុវត្ត, មាត្រា២១-របាយការណ៍, មាត្រា២២-ប្រសិទ្ធភាពនៃការវាយតម្លៃ, មាត្រា២៣-សន្និសីទភាគី, មាត្រា២៤-លេខាធិការដ្ឋាន, មាត្រា២៥-ដំណោះស្រាយជម្លោះ, មាត្រា២៦-ការធ្វើវិសោធនកម្មអនុសញ្ញា, មាត្រា២៧-ការអនុម័តនិងការធ្វើវិសោធនកម្មឧបសម្ព័ន្ធ, មាត្រា២៨-សិទ្ធិបោះឆ្នោត, មាត្រា២៩-ការចុះហត្ថលេខា, មាត្រា៣០-ការផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលរួម, មាត្រា៣១-ការចូលជាធរមាននៃអនុសញ្ញា, មាត្រា៣២-ខរក្សាសិទ្ធិ, មាត្រា៣៣-ការដកខ្លួនចេញពីអនុសញ្ញា, មាត្រា៣៤-ការិយាល័យតម្កល់ឯកសារ, មាត្រា៣៥-អត្ថបទយថាភូត។

យោងទៅលើការសិក្សាឯកសារពាក់ព័ន្ធនិងបទពិសោធរបស់ប្រទេសនានានៅក្នុងតំបន់ ការផ្តល់សច្ចាប័នចូលជាភាគីនៃអនុសញ្ញានេះនឹងនាំមកនូវប្រយោជន៍យ៉ាងច្រើនដល់ព្រះរាជាណាចក្រកម្ពុជា រួមមានៈ

**១. ផលប្រយោជន៍ផ្នែកនយោបាយ**

- បង្ហាញពីឆន្ទៈរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការចូលរួមជាមួយសហគមន៍អន្តរជាតិ ដើម្បីទប់ស្កាត់និងការពារគ្រោះថ្នាក់លើសុខភាពសាធារណៈនិងបរិស្ថាន ដែលបង្កឡើងដោយបារត
- លើកកម្ពស់កិត្យានុភាពជាតិ តាមរយៈការចូលរួមសន្និសីទនានាក្នុងនាមជាភាគីនៃអនុសញ្ញា ដើម្បីកាត់បន្ថយការបញ្ចេញនិងការសាយភាយបារតពីផលិតកម្មនិងប្រព័ន្ធផលិតកម្ម
- ចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តតាមរយៈសន្និសីទនានារបស់រដ្ឋជាភាគី។

**២. ផលប្រយោជន៍ផ្នែកសុខភាពនិងបរិស្ថាន**

- រួមចំណែកកាត់បន្ថយផលប៉ះពាល់ទៅលើសុខភាពប្រជាជននិងបរិស្ថានពិភពលោក
- ទប់ស្កាត់បានការធ្វើពាណិជ្ជកម្ម ការនាំចេញនិងការនាំចូល ការប្រើប្រាស់ ការកែច្នៃ និងការបោះចោលបារតនិងសំណល់មានផ្ទុកបារត ដោយមិនមានសុវត្ថិភាពបរិស្ថាន។

**៣. ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច**

- ការចូលជាភាគីនៃអនុសញ្ញានេះនឹងមិនបង្កផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចទេ ដោយសារព្រះរាជាណាចក្រកម្ពុជា មិនមែនជាប្រទេសផលិត ឬនាំចេញបារត ឬផលិតផលមានបន្ថែមបារត

- ទប់ស្កាត់ទាន់ពេលវេលានូវការនាំចូលបារតខុសច្បាប់ឬផលិតផលដែលមានផ្ទុកបារត ដែលនាំឱ្យខាតបង់ថវិកាជាតិក្នុងការគ្រប់គ្រងនៅពេលផលិតផលទាំងនោះក្លាយជាសំណល់
- ទទួលបានជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស គាំទ្រលើការបណ្តុះបណ្តាលធនធានមនុស្សនិងការពង្រឹងសមត្ថភាពស្ថាប័នជាតិ ដើម្បីចូលរួមអនុវត្តសកម្មភាពពាក់ព័ន្ធនឹងអនុសញ្ញា។

សរុបមក ការចូលជាភាគីនៃអនុសញ្ញាមីណាម៉ាតាស្តីពីបារតពុំមានផលប៉ះពាល់អវិជ្ជមានណាមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជាឡើយ ទោះបីត្រូវជាប់កាតព្វកិច្ចក្នុងការចូលរួមបង់ថវិកាបន្តិចបន្តួចក៏ដោយ។ ផ្ទុយទៅវិញ ការអនុវត្តអនុសញ្ញានេះនឹងចូលរួមចំណែកបំពេញបន្ថែមដល់ការអនុវត្តអនុសញ្ញាពហុភាគីក្នុងវិស័យគាំពារបរិស្ថានដែលកម្ពុជាបានចូលជាភាគី ហើយព្រមទាំងចូលរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល គោលនយោបាយកាត់បន្ថយភាពក្រីក្រ លើកកម្ពស់កិច្ចគាំពារបរិស្ថាន សំដៅឆ្ពោះទៅសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដើម្បីបញ្ជូនទៅសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ដែលរួមមាន២មាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភា មេត្តាពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាមីណាម៉ាតាស្តីពីបារត ដោយក្តីអនុគ្រោះ។

ថ្ងៃសុក្រ ១០ រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**